បកប្រែក្រៅផ្លូវការ

រាជធានីភ្នំពេញ, ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ២០២០

វេជ្ជបណ្ឌិត Laurence BARIL, MD, MPH, PhD
នាយកវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា
៥ មហាវិថីព្រះមុនីវង្ស (៩៣)
<u>**រាជធានីភ្នំពេញ**</u>

**លោកស្រីវេជ្ជបណ្ឌិត ឡូរ៉ង់ បារីល**

ខ្ញុំសរសេរលិខិតថ្លែងអំណរគុណនេះដើម្បីអរគុណ**លោកស្រី** និងក្រុមការងាររបស់វិទ្យាស្ថានប៉ាស្ទ័រកម្ពុជា សម្រាប់ជំនួយដ៏ប្រពៃ ដែលពួកគាត់បានផ្តល់ជូន ដើម្បីគាំទ្រដល់ការធ្វើតេស្តរកកូវីដ-១៩ លើមន្ត្រីរដ្ឋាភិបាលកម្ពុជា រួមទាំងរូបខ្ញុំផ្ទាល់ ព្រមទាំងមនុស្សទាំងអស់ដែលជាប់ពាក់ព័ន្ធផ្ទាល់ និងដោយប្រយោល នៅក្នុងព្រឹត្តិការណ៍ថ្ងៃទី៣ ខែវិច្ឆិកា ដោយសហការយ៉ាងជិតស្និទ្ធជាមួយក្រសួងសុខាភិបាល។ កាយវិការនេះ ពិតជាបង្ហាញយ៉ាងច្បាស់នូវការប្តេជ្ញាចិត្តយ៉ាងខ្លាំងក្លារបស់**លោកស្រី** ក្នុងការធ្វើការជាមួយរាជរដ្ឋាភិបាលកម្ពុជា ដើម្បីយកឈ្នះវិបត្តិសកលដែលពុំធ្លាប់មិនពីមុននេះ។

ទោះបីជាករណីកូវីដ-១៩ កំពុងកើនឡើងយ៉ាងឆាប់រហ័សនៅទូទាំងតំបន់ និងពិភពលោក ក៏ដោយ ខ្ញុំជឿជាក់ថា ដោយមានការគាំទ្រយ៉ាងខ្លាំងពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នៅក្រោមការដឹកនាំដ៏ឆ្លៀសវៃរបស់**លោកស្រី** ប្រទេសកម្ពុជានឹងអាចឆ្លងផុតពីការគំរាមកំហែងរួមជាសកលនេះ។

ជាថ្មីម្តងទៀត តាងនាមឱ្យរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមសំដែងនូវអំណរគុណយ៉ាងស្មោះ ជូនចំពោះ**លោកស្រី** និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា សម្រាប់កិច្ចខិតខំប្រឹងប្រែងមិនខ្លាចនឿយហត់ និងការគាំទ្រឥតប្រែប្រួលផ្តល់ជូនអាជ្ញាធរកម្ពុជាពាក់ព័ន្ធ ក្នុងការប្រយុទ្ធនឹងជម្ងឺរាតត្បាតសកលនេះ ដើម្បីសុខុមាលភាពរបស់ប្រជាជនកម្ពុជាទាំងមូល។

សូម**លោកស្រី** ទទួលនូវការគោរពរាប់អានអំពីខ្ញុំ និងសូមប្រសិទ្ធិពរ**លោកស្រី** ប្រកបដោយសុខភាពល្អ និងសូមឱ្យវិទ្យាស្ថានដ៏ល្បីល្បាញរបស់**លោកស្រី** កាន់តែទទួលបានជោគជ័យធំធេងបន្ថែមទៀត។

**ហ៊ុន សែន**

Samdech Akka Moha Sena Padei Techo HUN SEN
Prime Minister of the Kingdom of Cambodia

Phnom Penh, 19 November 2020

**Dr. Laurence BARIL, MD, MPH, PhD**
Director,
Institute Pasteur du Cambodge
5 Preah Monivong Blvd (93), Phnom Penh
**Phnom Penh**

**Dear Dr. Laurence BARIL,**

I am writing this letter of appreciation to thank you and your esteemed team of the Institute Pasteur du Cambodge for the kind assistance they have rendered in support of the testing for COVID-19, in close collaboration with the Ministry of Health, on Cambodian government officials, including myself, and all the people who have direct and indirect contact with the 3rd November's Event. This truly manifested your strong commitment to work with the Royal Government of Cambodia to overcome this unprecedented global crisis.

Despite the fact that the cases of COVID-19 are soaring across the region and the world, I am confident that with the strong support of the Institute Pasteur du Cambodge, under your wise leadership, Cambodia would be able to get through this global common threat.

Once again, on behalf of the Royal Government of Cambodia, I wish to express my sincere appreciation to you and the Institute Pasteur du Cambodge for the tireless efforts and constant supports provided to the relevant Cambodian authorities in fighting with this global pandemic for the well-being of Cambodian people as a whole.

Please accept, **Dr. Laurence BARIL**, the assurances of my high consideration and my best wishes for your good health and greater successes for your prominent Institute.

**HUN SEN**